ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

(10/4)

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងរដ្ឋប្បវេណី
លេខ: ៣០៤
ចុះថ្ងៃទី ១២-០៧-២០១១
សាលដីកា
លេខ: ២៩ ក្រV.អ
ចុះថ្ងៃទី ២២-០៩-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

រវាងដើមចោទឈ្មោះ [redacted] ថាច ភេទស្រី អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

និងចុងចម្លើយឈ្មោះ [redacted] សុឃីម ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិអូរអំបិល សង្កាត់អូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**អំពីអង្គហេតុ និងចំណុចវិវាទ:**

ក/ សាលក្រមដែលទាមទារដោយភាគី:

- ភាគីដើមចោទសុំឲ្យតុលាការចេញ សាលក្រមដូចតទៅ:

- សុំបញ្ជាក់ទទួលស្គាល់សិទ្ធិកាន់កាប់ និងប្រគល់អចលនវត្ថុ នៃផ្ទះល្វែងទំហំ ៦៨ម៉ែត្រការ៉េដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខ: ០៣ គរជ/លអប ចុះថ្ងៃទី០១-៣-១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឲ្យទៅឈ្មោះ [redacted] ថាច ជាម្ចាស់កម្មសិទ្ធ ។

- សុំឲ្យចុងចម្លើយឈ្មោះ [redacted] សុឃីម ចុះចេញពីផ្ទះល្វែងទំហំ ៦៨ម៉ែត្រការ៉េដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ/ល អប ចុះថ្ងៃទី០១-៣-១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ មានជ័យ ។

- ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ពន្ធបណ្តឹង និងប្រាក់ប្រដាប់ក្តី ។

- ទាមទារឲ្យចុងចម្លើយសងជំងឺចិត្តការខាតបង់ពេលវេលាចំនួន ៥.០០០.០០០៛(ប្រាំលានរៀល) ។

ខ/ ការពន្យល់អង្គហេតុ មានដូចតទៅ:

កាលពីឆ្នាំ២០០១ ឈ្មោះ [redacted] ថាច បានទិញផ្ទះ និងដីសំរាប់សង់ផ្ទះល្វែងពីឈ្មោះ [redacted] អេងណៃ និងប្តីឈ្មោះ [redacted] ហួរ ទំហំ ៦៨ម៉ែត្រការ៉េ ដែលមាននៅក្នុងប័ណ្ណលក់ ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣



Scanned with CamScanner

គរជ/លអប ចុះថ្ងៃទី០១-៣-១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ក្នុងតម្លៃ ២៧០.០០០B (ពីររយចិតសិបពាន់បាត) លុះដល់ឆ្នាំ២០០២ ឈ្មោះ [redacted] ថាច បានធ្វើការជួសជុល និងពង្រីកបន្ថែមលើចំណែកដីដែលនៅសល់ចំនួនមួយល្វែងទៀតបានជាពីរល្វែង ។ ក្នុងឆ្នាំ២០០៥ ឈ្មោះ [redacted] គីមហាង ត្រូវជាកូន របស់ឈ្មោះ [redacted] ថាច បានទទួលមរណៈភាពដោយគ្រោះថ្នាក់ចរាចរ ហើយក្រោយមកស្រាប់តែឈ្មោះ [redacted] សុឃីម ត្រូវជាកូនប្រសារបានបង្ខំឲ្យធ្វើបណ្តាំមរតកទៅឲ្យចៅ តែឈ្មោះ [redacted] ថាច ពុំយល់ព្រមហើយ ឈ្មោះ [redacted] សុឃីម បានចាក់សោរមិនឲ្យឈ្មោះ [redacted] ថាច ចូលទៅរស់នៅទើបទំនាស់កើតឡើង ។

- ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទលោក [redacted] ថ្លែងការណ៍ កូនក្តីខ្ញុំរស់នៅមិនចុះសំរុងគ្នា និងអ្នកស្រី [redacted] សុឃីម នៅក្នុងឆ្នាំ២០០៣ ក្នុងការទិញដូរផ្ទះនេះមានលិខិតស្នាមរបស់គណៈកម្មការផ្សារ មានទាំងលិខិតសាងសង់បន្ថែមទៀត មានបញ្ជីទិញគ្រឿងសំណង់ទៀតផង ។ សូមបញ្ជាក់ថា ផ្ទះនោះកូនក្តីខ្ញុំបានទិញពីឈ្មោះ [redacted] ហួរ និងប្រពន្ធឈ្មោះ [redacted] អេងណៃ ដោយមានលិខិតបញ្ជាក់របស់ចៅសង្កាត់ឈ្មោះ [redacted] ពេជ្រ ទៀតផង ។ មិនតែប៉ុណ្ណោះមានលិខិតប្រគល់ប្រាក់មានថ្លៃជួស ជុលផ្ទះ មូលហេតុដែលកូនក្តីខ្ញុំមិនរស់នៅ ព្រោះ លោកស្រី ឃីម បានចាក់សោរផ្ទះនោះ ។ ម្យ៉ាងទៀតកូនក្តីខ្ញុំមិនសូវយល់ដឹងអំពីផ្លូវច្បាប់ ហើយមានទាំងលិខិតប្រគល់ផ្ទះនោះឲ្យកូនក្តីខ្ញុំដោយគណៈកម្មការផ្សារទៀតផង ។ សូមបដិសេធនូវចម្លើយរបស់ចុងចោទ ព្រោះគាត់គ្មាននូវឯកសារដែលថា គាត់ទិញផ្ទះនោះឆ្នាំ១៩៩៩ ឡើយ រីឯកូនក្តីខ្ញុំបានទិញផ្ទះនោះមានលិខិតប្រគល់ប្រាក់ និងមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ។ ដូចនេះ សូមក្រុមប្រឹក្សាមេត្តាតម្កល់សាលក្រម សាលាដំបូងទុកជាបានការដដែល ។

- ការអះអាងរបស់ចុងចោទឈ្មោះ [redacted] សុឃីម ថ្លែងការណ៍ នាងខ្ញុំមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះ ព្រោះលុយដែលទិញផ្ទះនេះជាលុយនាងខ្ញុំ និងជា (លុយទិញដី) ក៏របស់នាងខ្ញុំដែរ ព្រោះពេលនោះក្នុងផ្សារមានលក់ដី ០១ កន្លែង ហើយពេលនោះនាងខ្ញុំចង់លក់ដូរនឹងគេក៏ខ្ចីលុយបងប្រុសនាងខ្ញុំចំនួន ៥៥០០$ និងលុយបាត ២៥០០០បាត ដោយឲ្យប្តីនាងខ្ញុំ និងម្តាយក្មេក ([redacted] ថាច) យកទៅទិញ កាលនោះផ្ទះនោះជាផ្ទះឈើទេ តែដោយនាងខ្ញុំទុកចិត្តម្តាយក្មេកពេកការសង់ផ្ទះទុកថា ប្តីអ្នកចេញលុយ ។ ក្នុងការទាមទារផ្ទះនោះទុកឲ្យតែកូនទេ សូមបញ្ជាក់ថា ផ្ទះនោះទិញឆ្នាំ១៩៩៩ ទិញភ្លាមនៅភ្លាមតែម្តង ។ ផ្ទះនោះអ្នកស្រី ហុង ថាច មិននៅជាមួយទេ ផ្ទះនោះទំហំ៦៨ម៉ែត្រការ៉េ អត់មានជញ្ជាំងខណ្ឌទេ ។ ដូចនេះនាងខ្ញុំសូម សំណូមពរ សូមទាមទារយកដីនោះមកវិញ ដើម្បីទុកឲ្យកូនទេ ។

## សំអាងហេតុ

១- បណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុឃីម ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២- លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ របស់មេធាវី [redacted] តំណាងឲ្យឈ្មោះ [redacted] ថាច ត្រឹមត្រូវតាមច្បាប់ ។

៣- ចុងចម្លើយឈ្មោះ [redacted] សុឃីម បានឆ្លើយអះអាងថា ដី និងផ្ទះល្វែងអំពីឈើទំហំ ៦៨ម² ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប័ណ្ណលក់លេខ ០៣ គរជ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ពេលទិញ គឺលេខ ០៣ គរជ/សអប ជាប្រាក់របស់ប្តីឈ្មោះ [redacted] គីមហាង (ស្លាប់ឆ្នាំ២០០៥) និងរូបខ្លួនដោយមានដើមចោទឈ្មោះ [redacted] ថាច ជាម្តាយក្មេកទៅ

ជាមួយដែរ ។ ខ្លួនបាន រៀបការនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ ក្រោយទិញហើយខ្លួន និងប្ដី-កូនបានរស់នៅ និងកាន់កាប់ផ្ទះនោះរហូតមក ។ នៅឆ្នាំ២០០២ មានការជួសជុល និងសាងសង់បន្ថែមលើដីដែលនៅសល់ជញ្ជាំងឥដ្ឋប្រក់ស័ង្កសីលើដីទំហំ ៦៨ម² ។ ចំពោះប្រាក់ជួសជុល និងសាងសង់បន្ថែមជាប្រាក់របស់ឪពុកម្ដាយទាំងសងខាង ។ ខ្លួនសុំគ្រប់គ្រងដីផ្ទះល្វែងទំហំ ៦៨ម² នេះពីព្រោះសព្វថ្ងៃខ្លួនកំពុងរស់នៅ និងកាន់កាប់ផ្ទះនោះ ។

៤- ការទិញលក់ដីផ្ទះល្វែងដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរ (ឯ.៤៩) លេខ ០៣ គរជ/សអប ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៣ ដែលអះអាងដោយដើមចោទឈ្មោះ [redacted] ថាច ថា បានទិញពីឈ្មោះ [redacted] ផេងណៃ និងប្ដីឈ្មោះ [redacted] ហួរ នោះមិនបានធ្វើជាកិច្ចសន្យាទិញ-លក់ជាលាយល័ក្ខនោះទេ មានតែលិខិតប្រគល់ប្រាក់ (ឯ.៤៨) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០១ ដែលបញ្ជាក់ថា ឈ្មោះ [redacted] ថាច បានប្រគល់ប្រាក់ថ្លៃទិញដីសំរាប់សង់ផ្ទះល្វែងទៅឲ្យឈ្មោះ [redacted] ផេងណៃ និង ប្ដីឈ្មោះ [redacted] ហួរ ចំនួន ២៧០.០០០បាត ។ ដូចនេះមិនអាចបញ្ជាក់បានថា អ្នកណាជាអ្នកទិញពិតប្រាកដ អាចជាឈ្មោះ [redacted] គឹមហាង ជាអ្នកទិញក៏អាចជឿបាន ។ ឯលិខិតប្រគល់ប្រាក់ថ្លៃឈ្នួលធ្វើផ្ទះ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ក៏ឈ្មោះ [redacted] ថាច ជាដើមចោទជាអ្នកប្រគល់ឲ្យឈ្មោះ [redacted] អាន ចំនួន ៩៥.០០០បាត ដែរ ។

៥- តាមលិខិតបញ្ជាក់ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ (ឯ.៤) របស់ឈ្មោះ [redacted] ផេងណៃ និងប្ដីឈ្មោះ [redacted] ហួរ បញ្ជាក់ថា បានលក់ផ្ទះល្វែងដែលស្ថិតនៅក្នុងទីផ្សារដើមគរ ឲ្យទៅអ្នកស្រី [redacted] ថាច កាលពីឆ្នាំ២០០១ ។ លិខិតបញ្ជាក់លេខ ៣០០ សអប ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ចៅសង្កាត់ឈ្មោះ [redacted] ពេជ្រ បញ្ជាក់ថា ឈ្មោះ [redacted] ថាច ជាអ្នកទិញផ្ទះ ២ល្វែងក្នុងទីផ្សារដើមគរពីឈ្មោះ [redacted] ហួរ និងអ្នកស្រី ជា ផេងណៃ (ឯ.៤០) ។

៦- តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ឈ្មោះ [redacted] ចាប បានឲ្យឈ្មោះ [redacted] សុឃីម ជាប្អូនស្រី និងប្ដីឈ្មោះ [redacted] គឹមហាង ខ្ចីប្រាក់ចំនួន ៥៥០០ ដុល្លាអាមេរិក ដើម្បីបង្គ្រប់ទិញដីនៅផ្សារដើមគរ កាលពីថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៩ ។ កិច្ចសន្យានេះបានបញ្ជាក់ដឹងឮពីមេភូមិឈ្មោះ [redacted] ស៊ាម ដែរ ។

៧- តាមចម្លើយរបស់ចុងចម្លើយតាំងតែពីពេលសំរុះសំរួល ផ្សះផ្សានៅសាលាសង្កាត់ រហូតដល់តុលាការនៅតែអះអាងថា ខ្លួន និងប្ដីជាអ្នកទិញដីផ្ទះល្វែងទំនាស់នេះ ឯប្រាក់ជួសជុលផ្ទះ និងសង់បន្ថែមជាប្រាក់ទាំងសងខាង គឺមានប្រាក់របស់ដើមចោទដែរ ។ ដោយសារតែប្ដីស្លាប់ឆ្នាំ ២០០៥ ទើបខ្លួនពុំមានឯកសារជាភស្តុតាងក្នុងរឿងនេះ ។ ឯដើមចោទក៏នៅតែអះអាងថា ខ្លួនជាអ្នកទិញដី ផ្ទះល្វែងទំនាស់នេះដែរ ហើយប្រាក់ទិញផ្ទះនេះខ្លួនទទួលបានពីប្អូននៅសហរដ្ឋអាមេរិក ឯឈ្នួលធ្វើផ្ទះជួសជុលផ្ទះជាប្រាក់របស់ខ្លួន ឃើញថា ដើមចោទ និងចុងចម្លើយសុទ្ធតែបានចំណាយប្រាក់ទិញដី ផ្ទះល្វែងទីផ្សារដើមគរដូចគ្នា ។ ដោយសារតែចុងចម្លើយឈ្មោះ [redacted] សុឃីម និងប្ដីឈ្មោះ [redacted] គឹមហាង បានរស់នៅ និងកាន់កាប់ផ្ទះនេះចាប់តាំងពីក្រោយទិញបាន រហូតដល់សព្វថ្ងៃមានតារាង ក៣ (ឯ.៨ វិក័យប័ត្រទឹក អគ្គិសនីជាភស្តុតាង) ហើយដើមចោទមិនបានរស់នៅជាមួយទេ ។ ដោយសារតែឈ្មោះ [redacted] គឹមហាង (ស្លាប់) ជាកូនដើមចោទតែម្នាក់ និងជាឪពុករបស់ក្មេងទាំងពីរនាក់បានចំណាយញើសឈាមក្នុងរឿងដីផ្ទះល្វែងនេះដែរ គប្បីប្រគល់សិទ្ធិកាន់កាប់អាស្រ័យផលដីផ្ទះមួយល្វែងទទឹង ៣ម៤០ ឲ្យចុងចម្លើយ ដើម្បីគ្រប់គ្រងទុកឲ្យកូនទាំងពីរតទៅតាមគោលការណ៍សមធម៌ ។

៨- សាលក្រមរដ្ឋប្បវេណីលេខ ០៤(ក) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ពុំមានលក្ខណៈត្រឹមត្រូវគប្បីលុបចោល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០៤(ក) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២- បែងចែកដី និងផ្ទះល្វែងទំហំ ៦៨ម² នៅទីផ្សារដើមគរភូមិអូរអំបិល ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ជាពីរតាមបណ្តោយដី:

ក- ប្រគល់សិទ្ធិកាន់កាប់អាស្រ័យផលលើដី និងផ្ទះល្វែងទទឹង ៣ម៤០ ឲ្យទៅឈ្មោះ [redacted] សុឃីម ដើម្បីគ្រប់គ្រងទុកឲ្យកូនទាំងពីរឈ្មោះ [redacted] វុនឈាង និង [redacted] វុនឈិង ។

ខ- ប្រគល់សិទ្ធិកាន់កាប់អាស្រ័យផលលើដី និងផ្ទះល្វែងទទឹង ៣ម៤០ ឲ្យទៅឈ្មោះ [redacted] ថាច ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៤- សាលដីកានេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើកផ្លូវប្តឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលដីកានេះ ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេខា: [redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០១១

ក្រឡាបញ្ជី

[redacted]

១៨៧

187



Scanned with CamScanner